**Joint Statement**

**Dispute Resolution Process between HAGL company and its subsidiaries and indigenous villages**

Banlung, Ratanakiri Province, Kingdom of Cambodia

19 January 2016

On 19 January 2016, community representatives of the fourteen indigenous villages (Ket, Nay, Kachout, Kres, Kam, Mass, Talao, Inn, Malik, Kanat Thom, Kak, Tanong, Muy and Peng) company representatives of HAGL, non-governmental organization (NGO) advisors, representatives of the Provincial Government of Ratanakiri and members of the Compliance Advisor Ombudsman (CAO) held a meeting in Banlung, Ratanakiri Province. These meetings were facilitated by the CAO of the International Finance Corporation (IFC).

The parties met to discuss the fundamental aspects of the implementation phase of the agreements made in September 2015 (the Agreement) between HAGL and the fourteen villages. This Agreement included commitments by HAGL to not clear or develop the lands of Ket, Nay and Kachout, as well as to repair and maintain roads and bridges in the villages that were damaged by its operation. It was further agreed that these commitments would be implemented by first organizing joint mapping trips to each of the affected villages.

Following the Agreement, the parties proceeded to plan the subsequent steps for a just resolution of the dispute, starting with boundary delimitation of HAGL's Economic Land Concession (ELC) within the village areas and village outlines altogether.

In preparation for the mapping trip to Ket, Kachout and Nay villages – the first of its kind in the present dispute – a meeting was held on the 19 January 2016 in which the relevant stakeholders shared plans and inputs for the following events.

**សេចក្តីថ្លែងការណ៍រួម**
**ស្តីពីដំណើរការដោះស្រាយវិវាទ រវាងក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ**
**និងក្រុមហ៊ុនបុត្រសម្ព័ន្ធ និង ភូមិជនជាតិដើមភាគតិច**

**ក្រុងបានលុង ខេត្តរតនគីរី ព្រះរាជាណាចក្រកម្ពុជា**

ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦

នៅថ្ងៃទី ១៩ ខែមករា ឆ្នាំ២០១៦ អ្នកតំណាងសហគមន៍ភូមិជនជាតិដើមភាគតិច ចំនួន១៤ភូមិ (ភូមិកេត ភូមិណាយ ភូមិកាជូត ភូមិក្រេះ ភូមិកាំ ភូមិម៉ាស ភូមិតាឡាវ ភូមិអ៊ីន ភូមិម៉ាលិក ភូមិកាណាត ភូមិកាក់ ភូមិតាណង ភូមិមុយ និង ភូមិពែង) អ្នកតំណាងក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ ទីប្រឹក្សាដែលជាអង្គការតំណាង អ្នកតំណាងរដ្ឋាភិបាលខេត្តរតនគិរី និង សមាជិកក្រុមការងារនៃការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយ វិវាទ (ស៊ីអេអូ) បានរៀបចំកិច្ចប្រជុំមួយក្នុងក្រុងបានលុង ខេត្តរតនគិរី។ កិច្ចប្រជុំនេះសម្របសម្រួលដោយ ការិយាល័យស៊ីអេអូ នៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (អាយអែហ្វស៊ី)។

ភាគីបានជួបគ្នាដើម្បីពិភាក្សាអំពីទិដ្ឋភាព មូលដ្ឋាន មួយចំនួននៃដំណាក់កាលអនុវត្តកិច្ចព្រមព្រៀងដែលបាន ធ្វើឡើងក្នុងខែកញ្ញា ឆ្នាំ២០១៥ (ហៅកាត់ថា កិច្ចព្រម ព្រៀង) រវាងក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ និង ភូមិទាំង១៤។ កិច្ចព្រមព្រៀងនេះ រួមមានការប្តេជ្ញាចិត្ត ពីខាង ភាគីក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ ថានឹងមិនធ្វើការឈូសឆាយ ឬ អភិវឌ្ឍន៍ទៅលើដីក្នុងភូមិកេត ភូមិណាយ និង ភូមិកាជូត ព្រមទាំងធ្វើការជួសជុល និងថែទាំផ្លូវ និងស្ពានក្នុងភូមិដែលខូចខាតដោយសារប្រតិបត្តិការរបស់ ក្រុមហ៊ុន។ មានការឯកភាពបន្ថែមទៀតថា ការប្តេជ្ញាចិត្តទាំងនេះនឹងត្រូវអនុវត្តតាមរយៈការរៀបចំឱ្យមានជាមុន នូវដំណើរចុះធ្វើការកំណត់ផែនទីរួមគ្នាទៅកាន់ភូមិនីមួយៗ ដែលរងផលប៉ះពាល់។

ក្រោយពេលមានកិច្ចព្រមព្រៀង ភាគីបានបន្តរៀបចំផែនការជំហានបន្ទាប់ សម្រាប់ការដោះស្រាយវិវាទមួយប្រកបដោយភាពយុត្តិធម៌ ដោយចាប់ផ្តើមពីការកំណត់ព្រំប្រទល់សម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនហ៊ាងអាញ់យ៉ាឡាយ នៅក្នុងបរិវេណភូមិ និង ខ្សែព្រំប្រទល់ភូមិ ជាមួយគ្នា។

ក្នុងការរៀបចំសម្រាប់ដំណើរចុះធ្វើការកំណត់ផែនទីទៅកាន់ភូមិកេត ភូមិកាជូត និងភូមិណាយ ដែលជាសកម្មភាព ដំបូងបង្អស់ក្នុងទម្រង់បែបនេះនៅក្នុងវិវាទបច្ចុប្បន្ន កិច្ចប្រជុំមួយត្រូវបានធ្វើឡើងនៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ ដែលអ្នកពាក់ព័ន្ធនានាបានធ្វើការចែករំលែកអំពីផែនការ និង មតិយោបល់សម្រាប់ព្រឹត្តិការណ៍

The mapping trips will be held from the 20-25 January 2016 and attended by Community Representatives, CAO representatives, members of the Provincial Government, NGO advisors and HAGL delegates. Each party is to provide their own mapping experts.

The parties are confident that the cooperation between the relevant stakeholders will provide a solid ground for subsequent activities aimed at implementing the Agreement and achieving a just resolution to the dispute.

បន្តបន្ទាប់។

ដំណើរចុះធ្វើការកំណត់ផែនទី នឹងធ្វើឡើងពីថ្ងៃទី ២០-២៥ ខែមករា ឆ្នាំ២០១៦ និងមានការចូលរួមពីអ្នកតំណាងសហគមន៍ អ្នកតំណាងការិយាល័យ ស៊ីអេអូ សមាជិករដ្ឋាភិបាលថ្នាក់ខេត្ត ទីប្រឹក្សាដែលជាអង្គការតំណាង និង ប្រតិភូក្រុមហ៊ុនហ័ងអាញ់យ៉ាឡាយ។ ភាគីនីមួយៗត្រូវផ្តល់អ្នកឯកទេសខាងធ្វើការកំណត់ផែនទីរៀងៗខ្លួន។

ភាគីជឿជាក់ថា កិច្ចសហប្រតិបត្តិការរវាងអ្នកពាក់ព័ន្ធនានា នឹងផ្តល់នូវមូលដ្ឋានមួយដ៏រឹងមាំសម្រាប់សកម្មភាពបន្តបន្ទាប់ទៀត ក្នុងគោលបំណងអនុវត្តកិច្ចព្រមព្រៀង និង សម្រេចឱ្យបាននូវដំណោះស្រាយមួយប្រកបដោយភាពយុត្តិធម៌ចំពោះវិវាទនេះ។